# ខន្ធបរិត្តវត្ថុ

## (រឿងខន្ធបរិត្ត)



សម័យនោះឯង ភិក្ខុ ១ រូបពស់ចឹកហើយក៏ស្លាប់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ។បេ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ បានជាដូច្នោះ ព្រោះភិក្ខុនោះមិនផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះបានផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ទាំង ៤ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើទុកជាពស់ចឹកក៏មិនបានស្លាប់ទេ ។ ត្រកូលស្តេចពស់ទាំង ៤ នោះ ដូចម្តេចខ្លះ ។ ត្រកូលស្តេចពស់ទាំង ៤ នោះ គឺ ត្រកូលស្តេចពស់ឈ្មោះវិរូបក្ខៈ ត្រកូលស្តេចពស់ឈ្មោះឯរាបថៈ ត្រកូលស្តេចពស់ឈ្មោះឆព្យាបុត្តៈ ត្រកូលស្តេចពស់ឈ្មោះកណ្ហាគោតមកៈ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបានជាដូច្នោះ ព្រោះភិក្ខុនោះមិនបានផ្សាយមេត្តាចិត្ត ទៅកាន់

ត្រកូលស្តេចពស់ទាំង ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុនោះ បានផ្សាយមេត្តាចិត្តទៅកាន់ត្រកូលស្តេចពស់ទាំង ៤ នេះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះបើទុកជាពស់ចឹកក៏មិនបានស្លាប់ទេ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្សាយមេត្តាចិត្ត ទៅកាន់ត្រកូលស្តេចពស់ ទាំង ៤ នេះ ដើម្បីគ្រប់គ្រងខ្លួន ដើម្បីរក្សាខ្លួន ដើម្បីការពារខ្លួន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវធ្វើមេត្តាចិត្តយ៉ាងនេះឯង ៖

វិរូបក្ខេហិ មេ មេត្តំ, មេត្តំ ឯរាបថេហិ មេ;
ឆព្យាបុត្តេហិ មេ មេត្តំ, មេត្តំ កណ្ហាគោតមកេហិ ច។

មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះ វិរូបក្ខៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះ ឯរាបថៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះ ឆព្យាបុត្តៈផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកត្រកូលស្តេចពស់ឈ្មោះ កណ្ហាគោតមកៈផង។

អបាទកេហិ មេ មេត្តំ, មេត្តំ ទ្វិបាទកេហិ មេ;
ចតុប្បទេហិ មេ មេត្តំ, មេត្តំ ពហុប្បទេហិ មេ។

មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមិនមានជើងផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងពីរផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងបួនផង មេត្តារបស់យើង (ចូរប្រព្រឹត្តទៅ) ជាមួយនឹងពួកសត្វមានជើងច្រើនផង។

មា មំ អបាទកោ ហឹសិ, មា មំ ហឹសិ ទ្វិបាទកោ;
មា មំ ចតុប្បទោ ហឹសិ, មា មំ ហឹសិ ពហុប្បទោ។

សត្វគ្មានជើង កុំបៀតបៀនយើង សត្វមានជើងពីរ កុំបៀតបៀនយើងឡើយ សត្វមានជើងបួន កុំបៀតបៀនយើង សត្វមានជើងច្រើន កុំបៀតបៀនយើងឡើយ ។

សព្វេ សត្តា សព្វេ បាណា, សព្វេ ភូតា ច កេវលា;
សព្វេ ភទ្រានិ បស្សន្តុ, មា កញ្ចិ បាបមាគមា។

ពួកសត្វទាំងអស់ផង ពួកបាណៈទាំងអស់ ផង ពួកភូតទាំងអស់ផង គ្រប់យ៉ាង សត្វទាំងអស់ (នោះ) ចូរឃើញនូវអារម្មណ៍ដ៏ចម្រើន អំពើដ៏អាក្រក់តិចតួចកុំបីមកឡើយ ។

អប្បមាណោ ពុទ្ធោ, អប្បមាណោ ធម្មោ;
អប្បមាណោ សង្ឃោ, បមាណវន្តានិ សរីសបានិ;
អហិវិច្ឆិកសតបទី, ឧណ្ណនាភិ សរពូមូសិកា។

ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃ មានគុណប្រមាណមិនបាន ពួកសត្តទីឃជាតិគឺ ពស់ ខ្យួយ ក្អែប ពីងពាង តុកកែ និង កណ្ដុរ ជាសត្វប្រកបដោយគុណសម្បត្តិ (តិច)។

កតា មេ រក្ខា កតា មេ បរិត្តា, បដិក្កមន្តុ ភូតានិ;
សោហំ នមោ ភគវតោ, នមោ សត្តន្នំ សម្មាសម្ពុទ្ធានំ។

ការរក្សាយើងបានធ្វើហើយ សេចក្ដីការពារយើង បានធ្វើហើយ សត្វទាំងឡាយចូរចៀសចេញទៅ យើងធ្វើកិរិយានមស្ការចំពោះព្រះមានព្រះភាគ ធ្វើកិរិយានមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំង ៧ ព្រះអង្គ (មានព្រះពុទ្ធទ្រង់ព្រះនាមវិបស្សីជាដើម)។

*(វិនយបិដក ចូឡវគ្គ ខុទ្ទកវត្ថុក្ខន្ធក បិដកលេខ ១០ ទំព័រ ១៣៩-៤១)*

*ដោយខេមរ អភិធម្មាវតារ*